ការប្រើវិធីបង្រៀន និងរៀនតាមបែបសហការដើម្បីបង្កើនសមត្ថភាពអានយល់ន័យរបស់សិស្សនៅក្នុងមុខវិជ្ជាភាសាខ្មែរ

Using Cooperative Learning to Enhance Reading Comprehension Students' Ability of Khmer Subject in Grade 6

នន កាន្និកា[1], សាំង មាសស្នួន[2]
NORN Kanika, SAINT Meassnguon

សង្ខិត្តន័យ

ការស្រាវជ្រាវនេះសិក្សាទៅលើការប្រើវិធីបង្រៀន និងរៀនតាមបែបសហការដើម្បីបង្កើនសមត្ថភាពអានយល់ន័យរបស់សិស្សក្នុងមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ទី៦។ គោលបំណងនៃការសិក្សាដើម្បបង្កើនសមត្ថភាពអានយល់ន័យរបស់សិស្សក្នុងមុខវិជ្ជាភាសាខ្មែរតាមរយៈការប្រើប្រាស់វិធីបង្រៀន និងរៀនតាមបែបសហការ (Cooperative Learning)។ ការសិក្សានេះត្រូវធ្វើឡើងតាមរយៈបរិមាណវិស័យ ដោយបានជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវបែប Pre-experimental Research Design ដែលមានតំណាងគំរូ 23 នាក់។ ឧបករណ៍ស្រាវជ្រាវដែលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យគឺទម្រង់តេស្ត (Pre-test និង Post-test) ទៅលើមេរៀនអំណានចំនួន 3 ដែលមានក្នុងសៀវភៅសិក្សាគោលរបស់សិស្ស។ លទ្ធផលបានបង្ហាញថាពិន្ទុ Post-test ($\bar{X}$ = 7.02) និងគម្លាតស្តង់ដា (SD = 1.54) ខ្ពស់ជាងពិន្ទុ Pre-test ($\bar{X}$ = 4.93) គម្លាតស្តង់ដា (SD = 1.72)។ ចំពោះសមត្ថភាពក្នុងការទទួលបានចំណេះដឹងពាក្យថ្មីកើនពី 0.80 ទៅ 0.95 ការត្រួតពិនិត្យចំណេះដឹងកើនពី 0.58 ទៅ 0.91 ការសង្ខេបកើនពី 0.67 ទៅ 1.28 ការសន្និដ្ឋានកើនពី 2.76 ទៅ 4.15។ លទ្ធផលការវិភាគស្ថិតិបានបញ្ជាក់ថា ($P < 0.05$) បង្ហាញថាការប្រើវិធីបង្រៀន និងរៀនតាមបែប Cooperative Learning បានធ្វើឱ្យសមត្ថភាពអានយល់ន័យរបស់សិស្សមានភាពប្រសើរឡើង។

ពាក្យគន្លឹះ៖ *ការបង្រៀន និងរៀនបែបសហការ សមត្ថភាពអាន សមត្ថភាពអានយល់ន័យ ភាសាខ្មែរថ្នាក់ទី៦*

១. គរុនិស្សិត ១២+៤ ជំនាន់ទី៣ (២០២៤-២០២៥) ឯកទេសបង្រៀនកម្រិតបឋមសិក្សា
២. គ្រូឧទ្ទេសដឹកនាំ

ABSTRACT

This research investigates the use of cooperative learning methods to enhance reading comprehension among sixth-grade students studying the Khmer language. The primary objective is to improve students' reading comprehension skills in the Khmer language through the application of a cooperative learning approach. The study employed a quantitative, pre-experimental research design with a sample of 23 participants. The data collection instruments were pre-test and post-test forms, which were based on three reading lessons from the students' official curriculum textbook. The results show that the post-test scores (mean = 7.02, standard deviation = 1.54) were significantly higher than the pre-test scores (mean = 4.93, standard deviation = 1.72). Detailed analysis of specific skills revealed improvements: Knowledge of new words increased from 0.80 to 0.95. Knowledge check scores rose from 0.58 to 0.91. Summarization skills improved from 0.67 to 1.28. Conclusion-drawing abilities increased from 2.76 to 4.15. A statistical analysis confirmed that the p-value was less than 0.05 ($P < .05$), indicating that the use of cooperative learning methods led to a significant improvement in students' reading comprehension abilities. The study concludes that implementing cooperative learning is an effective strategy for improving reading comprehension in Khmer language for sixth-grade students.

Key words: *Cooperative Learning, reading ability, reading comprehension, 6th-grade Khmer language.*

១. សេចក្តីផ្តើម

១.១ សារៈសំខាន់នៃការស្រាវជ្រាវ

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់កម្មវិធីសិក្សាជាច្រើនលើក។ ជាក់ស្តែង នៅឆ្នាំ ២០១៦ ក្រសួងបានកែទម្រង់ក្របខណ្ឌកម្មវិធីសិក្សាលើគ្រប់មុខវិជ្ជា និងកែសម្រួលទាំងម៉ោងសិក្សា ខ្លឹមសារ វិធីសាស្ត្រ ព្រមទាំងការអនុវត្ត។ បើក្រឡេកទៅមើលកម្មវិធីសិក្សាភាសាខ្មែរថ្នាក់ជាតិនៅកម្រិតបឋមសិក្សាបាន កំណត់យ៉ាងច្បាស់នូវសមត្ថភាពសំខាន់ៗចំនួន ៤ ក្នុងការបង្រៀន និងរៀនដោយនៅក្នុងនោះមាន៖ សមត្ថ ភាពស្តាប់ សមត្ថភាពនិយាយ សមត្ថភាពអាន និងសមត្ថភាពសរសេរ។ សមត្ថភាពអំណានត្រូវបានបែងចែកជា ៣ ផ្នែកទៀតមាន៖ការអានយល់ន័យ វេយ្យាករណ៍ និង ពាក្យចួន (ក្រសួងអប់រំ យុវជន និងកីឡា, ២០២៣)។

យោងទៅតាមប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុ វជន និងកីឡាភាសាខ្មែរជាមុខវិជ្ជាមូលដ្ឋានគ្រឹះមួយដ៏សំខាន់ក្នុងការសិក្សា (ហង់, ២០១៦)។ ក្រសួងអប់រំ យុ វជន និងកីឡា (២០១៨) បញ្ជាក់ថា នៅពេលសិស្សមានសមត្ថភាពអានបានល្អ (ចេះលើកដាក់សំឡេង គោរពសញ្ញាសម្ព័ន្ធ និងភាពស្ទាត់ជំនាញ) នឹងជួយឱ្យពួកគេមានសមត្ថភាពចងចាំ យល់ន័យ វិភាគ វាយតម្លៃ និងបង្កើតថ្មី។ សមត្ថភាពអានគឺជាកត្តាចម្បងក្នុងការរៀនសូត្រ គ្រូត្រូវបណ្តុះគំនិតឱ្យសិស្សចេះគិតយល់ន័យ លើមេរៀន ក៏ដូចជាអត្ថបទអំណានដែលបានអាចរួច។ ក្រសួងអប់រំ យុវជន និងកីឡា (២០២១) ចាត់ទុកអ្នក

អានពូកែជាអ្នកដែលអាចសង្ខេប ចងចាំ វិភាគ វាយតម្លៃនិងបូកសរុបអត្ថន័យ។ ដូច្នេះ ការអានយល់ន័យទាមទារឱ្យសិស្សប្រើការគិត និងវិភាគដើម្បីស្វែងយល់ខ្លឹមសារសំខាន់ៗក្នុងអត្ថបទ។

ដើម្បីបង្កើនការបង្រៀន និងរៀនរបស់គ្រូ និងសិស្សឱ្យកាន់តែមានភាពប្រសើរឡើងក្រសួងអប់រំបានបញ្ចូលវិធីសាស្ត្រថ្មីៗជាច្រើនទៅក្នុងប្រព័ន្ធអប់រំ (ឡុច, យិន, ប៉ូ, ២០១៩)។ វិធីសាស្ត្រទាំងនោះរួមមានៈ បែបរិះរកដោះស្រាយបញ្ហា គម្រោង អនុមានញែក អនុមានរួម ផែនទីគំនិត និងសហការ ដែលសុទ្ធសឹងតែមានយុទ្ធវិធីបង្រៀន និងរៀនខុសៗគ្នា។

ផ្អែកលើការស្រាវជ្រាវរបស់ Johnson et al. (1994) ការរៀនបែបសហការ (Cooperative Learning) ជំរុញឱ្យសិស្សចេះចែករំលែក និងជួយគ្នាជាក្រុម ពីព្រោះថាការខិតខំរបស់បុគ្គលម្នាក់ៗ មិនត្រឹមតែផ្តល់សារៈប្រយោជន៍ដល់ខ្លួនឯងប៉ុណ្ណោះទេ គឺថែមទាំងជួយឱ្យក្រុមទាំងមូលរីកចម្រើនផងដែរ។ មួយវិញទៀត យោងតាមការស្រាវជ្រាវរបស់ Bhadra (2002) ការរៀនតាមបែបសហការ (Cooperative Learning) គឺជាវិធីសាស្ត្រសិក្សាដែលតម្រូវឱ្យសិស្ស ចូលរួមយ៉ាងសកម្មជាក្រុមតូចៗ។ ការរៀនបែបសហការ (Cooperative Learning) មានគោលបំណងលើកកម្ពស់អន្តរកម្មវិជ្ជមាន ភាពជាអ្នកដឹកនាំ និងការគិតសុីជម្រៅ ដើម្បីសម្រេចលទ្ធផលសិក្សារួម (Saint, 2019)។ វិធីសាស្ត្រនេះបានផ្តល់សារៈប្រយោជន៍ជាច្រើនដល់សិស្សានុសិស្សដោយជួយឱ្យពួកគេទទួលបានចំណេះដឹងថ្មី ជំនាញសង្គម ជំនាញទំនាក់ទំនង និងការគិតកម្រិតខ្ពស់។ បន្ថែមពីនោះ ការសិក្សារបស់ Jalilifar (2010) បង្ហាញថាការរៀនសូត្រតាមបែបសហការ (Cooperative Learning) ពិតជាអាចជួយបង្កើនសមត្ថភាពយល់ន័យក្នុងការអានបានកាន់តែប្រសើរ។

១.២ បញ្ហាស្រាវជ្រាវ

ការស្ទង់មតិ SEA-PLM 2019 បានបង្ហាញថា គុណភាពសិក្សានៅអាស៊ីអាគ្នេយ៍នៅតែមានកម្រិតទាបដោយសិស្សានុសិស្សភាគច្រើន មិនអាចបំពេញតាមស្តង់ដាសិក្សាសកលបានឡើយ បើទោះបីជាមានការវិនិយោគច្រើនលើវិស័យអប់រំក៏ដោយ។ ជាក់ស្តែងកម្រិតអប្បបរមានៃការអានសម្រាប់សិស្សថ្នាក់ទី ៥ នៅប្រទេសហ្វីលីពីន កម្ពុជា មីយ៉ាន់ម៉ាមានតែ 10% ទៅ 11% ប៉ុណ្ណោះខណៈម៉ាឡេស៊ី 58% និងវៀតណាម 82% (SEA-PLM, 2020)។

តាមការស្រាវជ្រាវរបស់ Spencer និង Wagner (2018) បង្ហាញថាសិស្សនៅបឋមសិក្សាមួយចំនួនកំពុងជួបបញ្ហាមួយគឺ ពួកគេមានសមត្ថភាពអានពាក្យក្នុងអត្ថបទបានប៉ុន្តែមិនអាចយល់អត្ថន័យនៃអត្ថបទដែលបានអាន និងមិនអាចឆ្លើយសំណួរដែលទាក់ទងនឹងអត្ថបទនោះបាន។

១.៣ គោលបំណងស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវមានគោលបំណង បង្កើនសមត្ថភាពអានយល់ន័យរបស់សិស្សក្នុងមុខវិជ្ជាភាសាខ្មែរ នៅកម្រិតថ្នាក់ទី៦ តាមរយៈការប្រើវិធីបង្រៀន និងរៀនតាមបែបសហការ។

២. រុក្ខរុទ្ធិស្តី

២.១ ការអាន

ការអានជាជំនាញមូលដ្ឋានគ្រឹះ និងជាឆ្អឹងខ្នងនៃការសិក្សា ដែលមានសារៈសំខាន់ចំពោះការលូតលាស់ផ្ទាល់ខ្លួន (Joaquin & Imbat, 2024)។ វាជួយបង្កើនទំនុកចិត្ត ការយល់ដឹងទូលំទូលាយ ផ្តល់ចំណេះដឹង និងការគិតសុីជម្រៅ ដែលជាកត្តាសម្រេចភាពជោគជ័យក្នុងការសិក្សាពេញមួយជីវិត។

២.២ ការអានយល់ន័យ

ការអានយល់ន័យគឺជា ដំណើរការអន្តរកម្ម ដែលអ្នកអាន ស្រូបយកព័ត៌មាន ពីអត្ថបទភាសាដោយប្រើការគិតដើម្បីបង្កើនការយល់ដឹង។ លើសពីនោះការយល់ន័យពីការអានបានជួយបង្កើនទំនាក់ទំនងចំណេះដឹងជាមួយអ្នកដទៃ (Suyana, 2019)។ ការអានយល់ន័យគឺជាសកម្មភាពពហុមុខងារជាច្រើនដែលពាក់ព័ន្ធទាំងរាងកាយ និងដំណើរការយល់ន័យទៅលើខ្លឹមសារអត្ថបទនីមួយៗដែលយើងបានអាន (Gunawan, 2022)។

២.៣ សមត្ថភាពអានយល់ន័យ

សមត្ថភាពអានយល់ន័យគឺជាជំនាញដ៏សំខាន់មួយ ដែលជះឥទ្ធិពលលើទិដ្ឋភាពផ្សេងៗនៃជំនាញភាសា និងភាពជោគជ័យក្នុងការសិក្សា។ ការស្រាវជ្រាវដែលនេះក៏បានបង្ហាញពីទំនាក់ទំនងដ៏រឹងមាំមួយ រវាងសមត្ថភាពអានយល់ន័យ និងសមត្ថភាពសរសេរ ដោយសារអ្នកអានដែលមានជំនាញតែងតែមានសមត្ថភាពសរសេរប្រកបដោយគុណភាព (Nofitri & Noveria, 2020)។

២.៤ សមាសភាគនៃសមត្ថភាពអានយល់ន័យ

សមត្ថភាពអានយល់ន័យមានសមាសភាគចូលរួមដូចខាងក្រោម៖

១. ចំណេះដឹងអំពីពាក្យ (Vocabulary)

ចំណេះដឹងអំពីពាក្យថ្មីជាសមាសភាគមួយនៃការអានយល់ន័យដែលជាជំនាញ ឬសមត្ថភាពក្នុងការយល់អំពីពាក្យ និងអត្ថន័យរបស់ពាក្យថ្មីៗដែលមាននៅក្នុងអត្ថបទអំណាននីមួយៗ (Cain et al., 2004)។

២. ការត្រួតពិនិត្យចំណេះដឹង (Comprehension Monitoring)

យោងតាម Kim (2017) ដំណើរការមួយដែលអ្នកអានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំង វាយតម្លៃ និងត្រួតពិនិត្យកម្រិតយល់ដឹងរបស់ពួកគេអំពីអ្វីដែលកំពុងអានហៅថាការត្រួតពិនិត្យការយល់ដឹង។

៣. ការសង្ខេបឡើងវិញ (Summarization)

តាមការសិក្សាស្រាវជ្រាវរបស់ Mokeddem និង Houcine (2016) ការសង្ខេបអត្ថបទឡើងវិញពិតជាមានសារៈសំខាន់ណាស់ដល់ការបង្កើន និងវាស់ស្ទង់សមត្ថភាពយល់ន័យពីការអាន ព្រោះតម្រូវឱ្យសិស្សបង្ហាញពីការយល់ដឹងរបស់ពួកគេទាក់ទងនឹងអត្ថបទតាមរយៈការសរសេរ។

៤. ការសន្និដ្ឋាន (inferences)

ការសន្និដ្ឋាន (inferences) គឺជាព័ត៌មានដែលត្រូវបានទាញយកពីការចងចាំ ឬបង្កើតឡើងក្នុងអំឡុងពេលអាន ដើម្បីបំពេញព័ត៌មានដែលមិនមាននៅក្នុងអត្ថបទ (Elbro & Buch-Iversen, 2013)។ តាមតាមរយៈការភ្ជាប់ព័ត៌មានក្នុងអត្ថបទជាមួយចំណេះដឹងដែលមានស្រាប់ ការសន្និដ្ឋានជាជំនាញសំខាន់មួយដែលជួយអ្នកអានបង្កើនការយល់ន័យពេញលេញអំពីអត្ថបទ (Cain et al., 2004; Elleman & Oslund, 2019; Kendeou et al., 2016)។

២.៥ វិធីបង្រៀន និងរៀនតាមបែបសហការ

ការបង្រៀន និងរៀនបែបតាមបែបសហការ គឺជាវិធីសាស្ត្រដែលតម្រូវឱ្យសិស្សសិក្សាជាក្រុម និងបង្រៀនគ្នាទៅវិញទៅមក (រួមមានក្រុមសិក្សាតូចៗ គម្រោង ការរៀនផ្អែកលើបញ្ហា និងសហគមន៍សិក្សា) សម្រាប់មុខវិជ្ជា និងជំនាញជាច្រើន (Yang, 2023)។

២.៦ គោលការណ៍នៃការបង្រៀន និងរៀនតាមបែបសហការ

វិធីបង្រៀន និងរៀនតាមបែប សហការ (Cooperative Learning) ត្រូវបានអ្នកស្រាវជ្រាវជាច្រើនរកឃើញ និងអនុវត្តដោយផ្អែកលើគោលការណ៍សំខាន់ៗមួយចំនួនដែលអាស្រ័យទៅតាមបរិបទនៃការស្រាវជ្រាវនីមួយៗ។

យោងតាម (Al-Yaseen, 2014; Felder & Brent, 2007; Li & Lam, 2013; Saint, 2019) លើកឡើងថាដើម្បីកសាងមេរៀនពាក់ព័ន្ធ និងគំរូសិក្សាបែបសហការណ៍ក្នុងនោះមានធាតុរួមបញ្ចូល និងគោលការណ៍ចំនួន៥ ដូចតទៅ៖

១. ការពឹងពាក់គ្នាទៅវិញទៅមកជាវិជ្ជមាន (Positive interdependence)៖ សំដៅដល់សមាជិកក្រុមម្នាក់ៗត្រូវចូលរួម និងពឹងផ្អែកលើគ្នាទៅវិញទៅមកដើម្បីសម្រេចបាននូវគោលដៅរួមរបស់ក្រុម។

២. គណនេយ្យភាពបុគ្គល (Individual Accountability)៖ សិស្សទាំងអស់នៅក្នុងក្រុមមួយត្រូវតែទទួលខុសត្រូវចំពោះការងាររួម និង ការងារផ្ទាល់ខ្លួន ។

៣. អន្តរកម្មលើកទឹកចិត្តទល់មុខ (face-to-face incentive interactions)៖ ដើម្បីសម្រេចគោលដៅរួម សមាជិកត្រូវមានអន្តរកម្មជាមួយគ្នា ទាំងការផ្តល់មតិកែលម្អ ការជួយគាំទ្រ ការលើកទឹកចិត្ត និងការពិភាក្សាដេញដោលគ្នាទៅវិញទៅមក។

៤. ជំនាញសង្គម អន្តរបុគ្គល ការសហការណ៍ និងក្រុមតូច (Interpersonal social skills, collaboration and small groups)៖ សិស្សត្រូវបានលើកទឹកចិត្ត និងជួយអភិវឌ្ឍ ព្រមទាំងបានអនុវត្តនូវជំនាញសំខាន់ៗ ដូចជា ការកសាងទំនុកចិត្ត ភាពជាអ្នកដឹកនាំ ការសម្រេចចិត្ត និងការទំនាក់ទំនង។

៥. ដំណើរការក្រុម (Group processing)៖ សមាជិកក្រុមត្រូវ កំណត់គោលដៅ ពិពណ៌នាពីសកម្មភាព វាយតម្លៃ ការងារដែលកំពុងធ្វើ កំណត់អត្តសញ្ញាណការផ្លាស់ប្តូរដើម្បីបង្កើនប្រសិទ្ធភាពការងាររួម។

បើតាមការស្រាវជ្រាវដោយ Anderson (2019) បានផ្តោតលើគោលការណ៍ស្នូលចំនួន ២ នៃការសិក្សាតាមបែបសហការដែលក្នុងនោះមាន ៖

១. ការពឹងពាក់គ្នាទៅវិញទៅមកជាវិជ្ជមាន (Positive interdependence)៖ សំដៅដល់សមាជិកក្រុមម្នាក់ៗត្រូវចូលរួម និងពឹងផ្អែកលើគ្នាទៅវិញទៅមកដើម្បីសម្រេចបាននូវគោលដៅរួមរបស់ក្រុម។

២. គណនេយ្យភាពបុគ្គល (Individual Accountability)៖ សិស្សទាំងអស់នៅក្នុងក្រុមមួយត្រូវតែទទួលខុសត្រូវចំពោះការងាររួម និង ការងារផ្ទាល់ខ្លួន ។

២.៧ ក្របខណ្ឌគំនិត



៣. វិធីសាស្ត្រស្រាវជ្រាវ

៣.១ រចៀបវិធីស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះផងដែរ ត្រូវបានរៀបចំឡើងទៅតាមប្រភេទបរិមាណវិស័យ ដើម្បីទទួលបានទិន្នន័យច្បាស់លាស់ពីសិស្ស។ ដោយអ្នកសិក្សាបានជ្រើសរើសយកការរចនាការស្រាវជ្រាវដែលធ្វើការពិសោធន៍តែមួយថ្នាក់ (Pre-Experimental research Design)។ ចំពោះការរៀបចំក្រុមអ្នកស្រាវជ្រាវបានធ្វើឡើងតាមបែប One-Group Pretest-Posttest Research Design ដើម្បីធ្វើតេស្តសមត្ថភាពលើការអានយល់ន័យរបស់សិស្សមុន និងក្រោយការបញ្ចូលវិធីសាស្ត្រ Cooperative Learning (Shek et al., 2018)។ មួយវិញទៀតការប្រើប្រាស់ One-Group Pretest-Posttest Research Design មានគោលបំណងវាស់ស្ទង់

ការផ្លាស់ប្តូរសមត្ថភាពសិស្សតាមរយៈការប្រៀបធៀបលទ្ធផលពិន្ទុ Pre-test និង Post-test (Spurlock, 2018)។

៣.២ ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍តេស្តត្រូវបានបង្កើតឡើងដែលគិតទៅតាមកម្រិតយល់ដឹងរបស់ប្លូម (Bloom's taxonomy) ព្រមទាំងមានការវាយតម្លៃពីសំណាក់គ្រូឧទ្ទេសផងដែរ។ អ្នកស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍តេស្តដែលមាន៖

- វត្ថុបំណងតេស្ត៖ វាស់ស្ទង់កម្រិតសមត្ថភាពលើការអានយល់ន័យរបស់សិស្សថ្នាក់ទី៦
- សំណួរតេស្តដែលបានដាក់ឱ្យសិស្សអនុវត្តន៍ចែកចេញជា ៣ ប្រភេទធំៗ៖ ប្រភេទសំណួរជ្រើសរើស (កម្រិតងាយ និងមធ្យម) ៤ សំណួរ ប្រភេទសំណួរផ្គូរផ្គង (កម្រិតមធ្យម) ៣ សំណួរ និងប្រភេទសំណួរត្រិះរិះ (កម្រិតលំបាក) ៤ សំណួរ។
- សមាសភាគនៅក្នុងឧបករណ៍៖ ក្នុងការបង្កើតឧបករណ៍តេស្ត អ្នកស្រាវជ្រាវត្រូវស្វែងយល់អំពីគុណភាពនិងភាពជឿជាក់ថាការរៀបចំខ្លឹមសារ ការគ្រប់គ្រង និងនិតិវិធីដែលបានបង្កើតត្រូវគិតលើទម្រង់នៃសំណួរដូចខាងក្រោម៖

ក. សំណួរពហុជ្រើសរើសរយៈពេល ២៤នាទី (វាសស្ទង់សមត្ថភាពចំណេះដឹងពាក្យថ្មី និងត្រួតពិនិត្យការយល់ដឹង)

ខ. សំណួរផ្គូរផ្គងរយៈពេល ៨នាទី (វាស់ស្ទង់សមត្ថភាពសន្និដ្ឋានអំពីអត្ថបទ)

គ. សំណួរត្រិះរិះរយៈពេល ៨នាទី (វាស់ស្ទង់សមត្ថភាពក្នុងការសង្ខេបអត្ថបទឡើងវិញ)

- ការប្រើប្រាស់តេស្ត៖ Pre-Test គឺត្រូវប្រើប្រាស់នៅមុនពេលបញ្ចូលវិធីសាស្ត្របែបសហការ (cooperative learning) ចំពោះ Post-Test វិញគឺត្រូវប្រើនៅក្រោយពេលដំណើរបញ្ចូលវិធីសាស្ត្របែបសហការ (cooperative learning) ត្រូវបានបញ្ចប់។
- រយៈពេលប្រើប្រាស់ឧបករណ៍តេស្ត៖ តេស្តនេះបង្កើតឡើងដើម្បីប្រើក្នុងរយៈពេល ៤០ នាទីសម្រាប់ប្រើប្រាស់លើបុរេតេស្ត និងតេស្តបញ្ចប់។
- សុពលភាព៖ ដើម្បីឱ្យតេស្តមានសុពលភាព និងភាពជឿជាក់ អ្នកស្រាវជ្រាវត្រូវបង្កើតឧបករណ៍តេស្តដោយមានឯកសារពាក់ព័ន្ធជាគោល និងស្របតាមកម្មវិធីសិក្សាលម្អិតលើមុខវិជ្ជាភាសាខ្មែរ នៅកម្រិតបឋមសិក្សាដោយពិភាក្សាជាមួយគ្រូដឹកនាំ និងគ្រូណែនាំ។ លើសពីនោះមុននឹងដំណើរការឧបករណ៍តេស្តអ្នកស្រាវជ្រាវក៏បានបង្កើតទម្រង់វាយតម្លៃតេស្ត (IOC) ដែលឆ្លងកាត់ដោយគ្រូឯកទេសលើមុខវិជ្ជាភាសាខ្មែរផ្ទាល់ផងដែរក្នុងមានការត្រួតពិនិត្យ និងវាយតម្លៃ ហើយពិន្ទុដែលទទួលបានស្មើ 1 > 0.5 ដែលធ្វើឱ្យឧបករណ៍តេស្តមានសុពលភាព។

៣.៣ ការវិភាគទិន្នន័យ

ទិន្នន័យនោះត្រូវបានវិភាគតាមរយៈកម្មវិធី Microsoft Excel 2016 ពឹងផ្អែកលើទិន្នន័យដែលបានមកពីការធ្វើតេស្តប្រឡង។ ទិន្នន័យត្រូវបានបកស្រាយតាមបែបស្ថិតិពណ៌នា (descriptive statistics) សម្រាប់រកតម្លៃមធ្យម (M) គម្លាតស្តង់ដា (SD) និងកម្រិតពិន្ទុដើម្បីធ្វើការប្រៀបធៀបលទ្ធផលសិក្សារបស់សិស្សមុន និងក្រោយពេលនៃការធ្វើតេស្ត (Kaur et al., 2018; Mishra et al., 2019)។ អ្នកស្រាវជ្រាវក៏បានប្រើស្ថិតិបែបសន្និដ្ឋានតាមបែប paired sample t-Test សិក្សាពីតម្លៃ P-value សម្រាប់ធ្វើការប្រៀបធៀបលទ្ធ

ផលពិន្ទុរបស់សិស្សមុន និងក្រោយការអនុវត្តវិធីបង្រៀន និងរៀនតាមបែបសហការ (Cooperative Learning)។

៤. លទ្ធផលស្រាវជ្រាវ

តារាង ៤.១ *លទ្ធផលវាងការធ្វើតេស្តមុនពេល និងក្រោយពេលបង្រៀន*

Test	**ពិន្ទុពេញ**	n	$\bar{x}$	SD	df	t	p
Pre-Test	10	23	4.93	1.72	22	-10.41	0.00***
Post-Test			7.02	1.54			

តារាង ៤.១ លទ្ធផលពិន្ទុ Pre-Test មានមធ្យមភាគ x^{-}= 4.93 គម្លាតស្តង់ដា SD = 1.72 និងលទ្ធផលពិន្ទុ Post-Test វិញមានមធ្យមភាគ x^{-}= 7.02 គម្លាតស្តង់ដា SD = 1.54 ហេតុដូចនេះតម្លៃ p = 0.00 តូចជាង 0.05 បញ្ជាក់ថាការប្រើប្រាស់វិធីបង្រៀន និងរៀនតាមបែបសហការ (Cooperative Learning) ពិតជាបានធ្វើឱ្យសមត្ថភាពអានយល់ន័យរបស់សិស្សថ្នាក់ទី៦ មានការកើនឡើងជាងមុន។

តារាង ៤.២ *លទ្ធផលនៃការប្រៀបធៀបសមាសភាគ*

សមាសភាគ	ពិន្ទុពេញ	Pre-test		Post-test		t	p
	(10)	$\bar{x}$	SD	$\bar{x}$	SD		
ចំណេះដឹងពាក្យថ្មី	1	0.80	0.29	0.95	0.14	-2.61	0.01**
ការត្រួតពិនិត្យចំណេះដឹង	5	0.58	0.38	0.91	0.19	-4.38	0.00***
សង្ខេប	2	0.67	0.46	1.28	0.35	-8.69	0.00***
សន្និដ្ឋាន	2	2.76	1.04	4.15	0.89	-8.37	0.00***
Pre-test Post-test	10	4.93	1.72	7.02	1.54	-10.41	

P < .05

តារាង ៤.២ លទ្ធផលបង្ហាញថាមុនពេលប្រើប្រាស់វិធីបង្រៀន និងរៀនតាមបែបសហការសិស្សទទួលបានពិន្ទុ 0.80 ទៅលើលើចំណេះដឹងពាក្យថ្មី ប៉ុន្តែក្រោយការប្រើប្រាស់ Cooperative Learning ពិន្ទុមធ្យមភាគរបស់សិស្សកើនទៅដល់ 0.95។ ការត្រួតពិនិត្យចំណេះដឹងសិស្សទទួលបានត្រឹមតែ 0.58 ប៉ុណ្ណោះបន្ទាប់ពីការអនុវត្ត Cooperative Learning ពិន្ទុមធ្យមភាគពួកគេទទួលបាន 0.91។ ចំពោះការសង្ខេបសិស្សទទួលបានពិន្ទុ 0.67 ទៅ 1.68 ក្រោយការប្រើប្រាស់វិធីបង្រៀន និងរៀនបែបសហការ។ រីឯមធ្យមភាគនៃពិន្ទុក្នុងការសន្និដ្ឋានសិស្សទទួលបាន 2.76 ប៉ុន្តែក្រោយការប្រើប្រាស់ Cooperative Learning សិស្សទទួលបានពិន្ទុមធ្យមដល់ទៅ 4.15 ។

៥. ការពិភាក្សា

គោលបំណងស្រាវជ្រាវ៖ បង្កើនការអានយល់ន័យដល់សិស្សក្នុងមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ទី៦ តាមរយៈការប្រើប្រាស់វិធីបង្រៀន និងរៀនតាមបែប Cooperative Learning។ ក្នុងការស្រាវជ្រាវបង្ហាញថាក្រោយបញ្ចូលវិធីសាស្ត្រសិក្សាតាមបែបសហការ សិស្សទទួលបានពិន្ទុមធ្យមភាគគួរឱ្យកត់សម្គាល់ពោលគឺ 7.02 គម្លាតស្តង់ដា 1.54បើប្រៀបធៀបទៅនឹងមុនពេលបញ្ចូលវិធីសាស្ត្រដោយក្នុងនោះសិស្សទទួលបានពិន្ទុ

មធ្យមភាគត្រឹមតែ 4.93 និងគម្លាតស្តង់ដា 1.72 ប៉ុណ្ណោះ។ ជាក់ស្តែងនៅក្នុងការបញ្ចូលវិធីសាស្ត្រ Cooperative Learning អ្នកស្រាវជ្រាវបានអនុវត្តទៅលើគោលការណ៍នៃវិធីសាស្ត្រសហការទាំងស្រុង។

ការសិក្សារបស់ Carrillo et al. (2019) បញ្ជាក់ថាគោលការណ៍នៃការពឹងពាក់គ្នាទៅវិញទៅមកជាវិជ្ជមាន និងអន្តរកម្មលើកទឹកចិត្តនៅពេលដែលពួកគេសហការគ្នាបំពេញកិច្ចការងារជាមួយគ្នា ជួយឱ្យសិស្សចេះស្វែងរកអត្ថន័យនៃពាក្យថ្មី ជួយឱ្យសិស្សមានប្រាស្រ័យទាក់ទងល្អក្នុងក្រុម ចេះសួរគ្នាទៅវិញទៅមកនៅពេលមានចំណុចណាមួយមិនយល់ច្បាស់ដើម្បីជាការត្រួតពិនិត្យចំណេះដឹងរបស់សមាជិកក្រុម ជួយសិស្សកំណត់បាននូវព័ត៌មានព្រមទាំងគំនិតសំខាន់ៗដើម្បីធ្វើការសង្ខេបអត្ថបទ លើសពីនោះវាក៏បានជួយឱ្យសិស្សធ្វើការរួមគ្នាដើម្បីប្រមូលខ្លឹមសារសំខាន់ៗពីអត្ថបទដែលបានសិក្សា និងចំណេះដឹងផ្ទាល់ខ្លួនសម្រាប់ការទាញសេចក្តីសន្និដ្ឋានដែលមិនត្រូវបានបញ្ជាក់ដោយផ្ទាល់ក្នុងអត្ថបទ។

ចំណែកការសិក្សារបស់ Pan និង Wu (2013) បង្ហាញថាការអនុវត្តរួមបញ្ចូលគ្នានូវគោលការណ៍ទាំងអស់នៃវិធីបង្រៀន និងរៀនតាមបែបសហការនឹងធ្វើឱ្យសិស្សចេះជួយគ្នាទៅវិញទៅមកក្នុងការបកស្រាយពាក្យថ្មី ឬឃ្លាដែលមិនច្បាស់លាស់តាមរយៈការពិភាក្សានិងការចែករំលែកចំណេះដឹងពាក្យថ្មីៗ។ មួយវិញទៀតនោះសិស្សក៏មានជំនាញនៅក្នុងការកំណត់បាននៅអត្តសញ្ញាណរបស់ពាក្យ ឃ្លា ឬគំនិតដែលពិបាកយល់ហើយបន្ទាប់មកសួរកការបំភ្លឺពីមិត្ត
រួមក្រុម។ បន្ថែមពីនេះសិស្សត្រូវបានលើកទឹកចិត្តឱ្យសង្ខេបខ្លឹមសារសំខាន់ៗនៃអត្ថបទឡើងវិញ ដែលសកម្មភាពនេះដែរបានជួយពួកគេក្នុងការយល់ន័យ គំនិតសំខាន់ៗក្នុងអត្ថបទ។

ការស្រាវជ្រាវមួយរបស់ Gupta និង Ahuja (2014) ការអនុវត្តគោលការណ៍សំខាន់ៗទាំងអស់នៃ (Cooperative Learning) បានរួមបញ្ចូលសកម្មភាពសម្រាប់សិក្សាពាក្យថ្មីៗក្នុងនោះដូចជាការប្រើប្រាស់បរិបទការពិភាក្សាអត្ថន័ពាក្យក្នុងក្រុម និងការអនុវត្តពាក្យ។ លើសពីនោះសិស្សរៀនពីរបៀបត្រួតពិនិត្យការយល់ដឹងរបស់ពួកគេផ្ទាល់ ដោយកំណត់អត្តសញ្ញាណចំណុចដែលពួកគេមិនយល់ ហើយស្វែងរកការបំភ្លឺពីមិត្តភក្តិ ឬគ្រូ។ តាមរយៈការពិភាក្សានិងការសហការគ្នាលើការសិក្សាអត្ថបទ សិស្សត្រូវបានលើកទឹកចិត្តឱ្យទាញការសន្និដ្ឋាន និងពង្រីកការយល់ដឹងរបស់ពួកគេ។

៦. សរុបសេចក្តី

ការសិក្សាស្រាវជ្រាវនេះដែរមានគោលបំណងប្រើប្រាស់វិធីបង្រៀន និងរៀនតាមបែបសហការ (Cooperative Learning) ដើម្បីបង្កើនសមត្ថភាពអានយល់ន័យរបស់សិស្សនៅក្នុងមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ទី៦។ ចំពោះការស្រាវជ្រាវនេះបានបង្ហាញលទ្ធផលឱ្យឃើញថាការប្រើប្រាស់វិធីបង្រៀន និងរៀនតាមបែប Cooperative Learning ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនសមត្ថភាពអានយល់ន័យដល់សិស្សថ្នាក់ទី ៦ ពិតប្រាកដមែនដោយមានការកើនឡើងគួរឱ្យកត់សម្គាល់នូវពិន្ទុមធ្យមភាគ ក្រោយពេលអនុវត្តន៍វិធីសាស្ត្របង្រៀន និងរៀនតាមបែបនេះ។

៧. អនុសាសន៍

អ្នកស្រាវជ្រាវសូមអនុញ្ញាតិផ្តល់ជាអនុសាសន៍មួយចំនួន៖ លោកគ្រូ អ្នកគ្រូគួរស្វែងយល់ឱ្យបានកាន់តែច្បាស់អំពីគោលការណ៍ Cooperative Learning និងរបៀបក្នុងការអនុវត្ត។ គោលការណ៍នៃការបង្រៀន និងរៀនតាមបែប Cooperative Learning ការពឹងពាក់គ្នាទៅវិញទៅមកជាវិជ្ជមាន (Positive Interdependence)៖ សិស្សក្នុងក្រុមត្រូវពឹងផ្អែកគ្នាទៅវិញទៅមកដើម្បីសម្រេចគោលដៅរួម។ គណនេយ្យ

ភាពបុគ្គល (Individual Accountability)៖ សមាជិកម្នាក់ៗក្នុងក្រុមមានទំនួលខុសត្រូវលើការងាររបស់ខ្លួន ហើយត្រូវយល់ច្បាស់ពីខ្លឹមសារមេរៀន។ អន្តរកម្មលើកទឹកចិត្ត (Promotive Interaction)៖ សិស្សត្រូវមានឱកាសធ្វើអន្តរកម្មជាមួយគ្នា ដូចជាការជួយពន្យល់គ្នាទៅវិញទៅមក និងការចែករំលែកគំនិត។ ជំនាញសង្គម (Social Skills)៖ សិស្សទាំងអស់នឹងត្រូវរៀនពីជំនាញសង្គមសំខាន់ៗ ដូចជាការស្តាប់ ការទំនាក់ទំនង និងការដោះស្រាយបញ្ហាជាមួយគ្នា។ ដំណើរការក្រុម (Group Processing)៖ ក្រុមត្រូវមានការពិភាក្សា និងវាយតម្លៃអំពីរបៀបដែលពួកគេធ្វើការជាមួយគ្នា ដើម្បីកែលម្អការសហការនៅពេលក្រោយ។ ការស្រាវជ្រាវពេលក្រោយគួរជ្រើសរើសយកពីរថ្នាក់មកធ្វើការប្រៀបធៀបដើម្បីស្វែងរកលទ្ធផលនៃការប្រើប្រាស់វិធីសាស្ត្រ Cooperative Learning ឱ្យបានកាន់តែច្បាស់លាស់ និងមើលថាយុទ្ធវិធីណាមួយនៃ Cooperative Learning ដែលប្រើទៅសិស្សងាយយល់និងមិនងាយធុញទ្រាន់។ មួយវិញទៀតការស្រាវជ្រាវពេលក្រោយគួរមានការប្រមូលទិន្នន័យដោយប្រើប្រាស់ទម្រង់សង្កេតមកជាមួយផងពោលគឺដើម្បីស្រួលក្នុងការសង្កេតមើលពីឥរិយាបថសិក្សារបស់សិស្សឱ្យបានកាន់តែច្បាស់លាស់នៅរវាងមុន និងក្រោយការបញ្ចូលវិធីសាស្ត្រ។

៨. ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា.(2023). *ឯកសារជំនួយស្មារតីដើម្បីកែលម្អការសិក្សាឆ្លើយតបនឹងរង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៦. បោះពុម្ពផ្សាយៈ ក្រសួងអប់រំយុវជន និង កីឡា*

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន.(2016). *គោលនយោបាយនិងការគ្រប់គ្រងវិស័យអប់រំ.ភ្នំពេញ, គ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា*

ប៉ូ ប៊ុន្តន, ឡុច ចាន់ថន, ឃិន វណ្ណី.(2019). វិធីសាស្ត្របង្រៀន. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ព ឯកសារខ្មែរ.

នាយកដ្ឋានគុណភាពអប់រំ.(2020). *ឯកសារជំនួយស្មារតីពីការអភិវឌ្ឍវិញ្ញាសាប្រឡងឆមាសនៅកម្រិតមធ្យមសិក្សាបឋមភូមិ .ភ្នំពេញ,កម្ពុជា*

ឯកសារបរទេស

Anderson, J. (2019). *Cooperative learning: Principles and practice. English Teaching Professional, 121*(1), 4-6.

Al-Yaseen, W. S. (2014). Cooperative learning in the EFL classroom. In International Academic Conference Proceedings (pp. 92-98).

Bhadra, A. (2002). A REFLECTIVE CLASSROOM PRACTICES THROUGH COOPERATIVE LEARNING. *Elementary School Journal*, *103*(1), 75-91.

Cain, K., Oakhill, J., & Bryant, P. (2004). Children's reading comprehension ability: Concurrent prediction by working memory, verbal ability, and component skills. *Journal of educational psychology*, *96*(1), 31.

Carrillo, N. M. R., Labre, M. G. P., & Valle, V. V. Y. (2019). The effects of cooperative learning on reading comprehension. Explorador Digital, 3(3.1), 143-163.

Elbro, C., & Buch-Iversen, I. (2013). Activation of background knowledge for inference making: Effects on reading comprehension. Scientific studies of reading, 17(6), 435-452.

Elleman, A. M., & Oslund, E. L. (2019). Reading comprehension research: Implications for practice and policy. Policy insights from the behavioral and brain sciences, 6(1), 3-11. https://doi.org/10.1177/2372732218816339

Felder, R. M., & Brent, R. (2007). Cooperative learning. Active learning: Models from the analytical sciences, 970, 34-53.

Gupta, M., & Ahuja, J. (2014). Cooperative integrated reading composition (CIRC): Impact on reading comprehension achievement in English among seventh graders. *IMPACT: International Journal of Research in Humanities, Arts and Literature*, *2*(5), 37-46.

Gunawan, I. (2022). Customer loyalty: The effect customer satisfaction, experiential marketing and product quality. KINERJA: Jurnal Manajemen Organisasi dan Industri, 1(1), 35-42.

Jalilifar, A. (2010). The effect of cooperative learning techniques on college students′ reading comprehension. *System*, *38*(1), 96-108.

JOAQUIN, S. R., & IMBAT, A. U. (2024). Game-Based Learning in Reading Pedagogy: A Review.

Johnson, D. W. (1994). The new circles of learning: Cooperation in the classroom and school. *Association for Supervision and Curriculum Development*.

Kendeou, P., McMaster, K. L., & Christ, T. J. (2016). Reading comprehension: Core components and processes. Policy insights from the behavioral and brain sciences, 3(1), 62-69. https://doi.org/10.1177/2372732215624707

Kim, Y. (2017). Why the Simple View of Reading Is Not Simplistic: Unpacking Component Skills of Reading Using a Direct and Indirect Effect Model of Reading (DIER). Scientific studies of reading, 21, 310-333. https://doi.org/10.1080/10888438.2017.1291643

Kaur, P., Stoltzfus, J., & Yellapu, V. (2018). Descriptive statistics. International Journal of Academic Medicine, 4(1), 60-63.

Li, M. P., & Lam, B. H. (2013). Cooperative learning. The Hong Kong Institute

of Education, 1, 33.

Mokeddem, S., & Houcine, S. (2016). Exploring the relationship between summary writing ability and reading comprehension: Toward an EFL writing-to-read instruction. Mediterranean Journal of Social Sciences, 7(2), 197-205. https://doi.org/Doi:10.5901/mjss.2016.v7n2s1p197

Mishra, P., Pandey, C. M., Singh, U., Gupta, A., Sahu, C., & Keshri, A. (2019). Descriptive statistics and normality tests for statistical data. Annals of cardiac anaesthesia, 22(1), 67-72.

Nofitri, Z., & Noveria, E. (2020). Hubungan kemampuan membaca pemahaman dengan kemampuan menulis. Jurnal Pendidikan Bahasa Dan Sastra Indonesia, 9(3), 80-86.

Pan, C. Y., & Wu, H. Y. (2013). The cooperative learning effects on English reading comprehension and learning motivation of EFL freshmen. English Language Teaching, 6(5), 13-27.

S., C., Shek, D., & Chen, J. (2018). Correction to: Changes in the Participants in a Community-

Based Positive Youth Development Program in Hong Kong: Objective Outcome Evaluation Using a One-Group Pretest-Posttest Design. Applied Research in Quality of Life, 1-2. https://doi.org/10.1007/S11482-018-9643-Y.

Spencer, M., & Wagner, R. K. (2018). The comprehension problems of children with poor reading comprehension despite adequate decoding: A meta-analysis. *Review of educational research*, *88*(3), 366-400.

Spurlock, D. (2018). The Single-Group, Pre- and Posttest Design in Nursing Education Research: It's Time to Move on.. The Journal of nursing education, 57 2, 69-71 . https://doi.org/10.3928/01484834-20180123-02.

Saint, M., (2019). Cooperative learning and conflict resolution: Essential 21st century skills. *21st century skills: Rethinking how students learn*, 201-219.

Suyana, U. M., & Agung, R. M. (2019). *The impact of tourism growth on inclusive economic growth and changes in economic structure in Bali Province, Indonesia. Russian Journal of Agricultural and Socio-Economic Sciences, 96*(12), 92-100.

Yang, X. (2023). A historical review of collaborative learning and cooperative learning. TechTrends, 67(4), 718-728